ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
លេខ ៣៦៧ ព.ណ ខកល.ប្រក

# ប្រកាស
# ស្តីពី
# ការកែសម្រួលភារកិច្ចជូនមន្ត្រីជាន់ខ្ពស់នៃក្រសួងពាណិជ្ជកម្ម ដើម្បីពិនិត្យ និងចុះហត្ថលេខាលើការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ នាំចេញទៅក្រៅប្រទេស

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញប្រកាសអន្តរក្រសួងលេខ ២៣៣ ព.ណ បអព.ប្រក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការកែសម្រួល នីតិវិធីក្នុងការបំពេញបែបបទនាំចេញទំនិញទៅក្រៅប្រទេស
- បានឃើញប្រកាសអន្តរក្រសួងលេខ ១៦៤៣ សហវ.ប្រក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការកែប្រែកម្រងសេវាសាធារណៈ នៃតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ ៩៨៥ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម។
- បានឃើញប្រកាសលេខ៣១៩៨ ពណ.ខកល ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៦ ស្តីពីនីតិវិធីនៃការស្នើសុំ និងការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញគ្រប់ទម្រង់ តាមប្រព័ន្ធស្វ័យប្រវត្តិកម្មរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមការចាំបាច់ក្នុងការកែទម្រង់ការងាររបស់ក្រសួងពាណិជ្ជកម្ម។

## សម្រេច

**ប្រការ ១.-**

ត្រូវបានកែសម្រួលភារកិច្ចជូនរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយក តំណាងក្រសួងពាណិជ្ជកម្មប្រចាំរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស និងប្រធាន ឬអនុប្រធានមន្ទីរពាណិជ្ជកម្មខេត្ត មានព្រំដែនជាប់ជាមួយព្រះរាជាណាចក្រថៃឡង់ដ៍ សាធារណរដ្ឋសង្គមនិយមវៀតណាម និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ឱ្យពិនិត្យ

និងសម្រេចចុះហត្ថលេខាលើការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញនាំចេញទៅក្រៅប្រទេស សំដៅសម្រួល និងពង្រឹងយន្តការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម ឲ្យបានកាន់តែប្រសើរជាងមុន។

**ប្រការ ២.-**

- វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញទម្រង់អេ (A) សម្រាប់ការនាំចេញទំនិញទៅបណ្តាប្រទេសជាសមាជិកសហគមន៍អឺរ៉ុប ដែលមានតម្លៃនាំចេញលើសពី ៦.០០០ (ប្រាំមួយពាន់) អឺរ៉ូ និងលើសពី ៨០០ (ប្រាំបីរយ) ដុល្លារសហរដ្ឋអាមេរិកសម្រាប់នាំចេញទៅកាន់ទិសដៅផ្សេងទៀត ត្រូវពិនិត្យ និងចុះហត្ថលេខាដោយរដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការ ដោយពុំចាំបាច់ដាក់ឆ្លងការពិនិត្យនិងយល់ព្រមដោយថ្នាក់អគ្គនាយកឡើយ។
- វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញគ្រប់ទម្រង់ សម្រាប់នាំចេញទំនិញទៅកាន់គ្រប់គោលដៅ លើកលែងតែ វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញទម្រង់អេ (A) ដូចមានចែងក្នុងចំណុចទី១ នៃប្រការ២ ក្នុងប្រកាសនេះ និងលើកលែងវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញទម្រង់ឌី (D) សម្រាប់នាំចេញទំនិញ កសិផលទៅកាន់ប្រទេសមានព្រំដែនជាប់ជាមួយព្រះរាជាណាចក្រកម្ពុជា ត្រូវចុះហត្ថលេខាដោយថ្នាក់ ដឹកនាំអគ្គនាយកសេវាពាណិជ្ជកម្ម។
- វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញទម្រង់ឌី (D) សម្រាប់នាំចេញទំនិញកសិផលដោយអ្នកនាំចេញ ដែលមានទីស្នាក់ការនៅក្នុងខេត្តស្ថិតក្រោមសមត្ថកិច្ចឆ្លោះទៅកាន់ប្រទេសមានព្រំដែនជាប់ជាមួយព្រះរាជាណាចក្រកម្ពុជា ត្រូវចុះហត្ថលេខាដោយប្រធាន ឬអនុប្រធានមន្ទីរពាណិជ្ជកម្មខេត្ត (តាមឧបសម្ព័ន្ធគំរូហត្ថលេខារបស់ប្រធាន និងអនុប្រធានមន្ទីរពាណិជ្ជកម្មខេត្ត) នៅក្រោយពេលដែលក្រុមហ៊ុនទទួលបានការឯកភាពពីថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្ម តាមប្រព័ន្ធស្វ័យប្រវត្តកម្មរបស់ក្រសួងពាណិជ្ជកម្មរួចហើយ។ ក្នុងករណីមានតម្រូវការចាំបាច់ ក្រុមហ៊ុនអាចដាក់ពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញទម្រង់ឌី (D) នៅទីស្តីការក្រសួងពាណិជ្ជកម្មបាន ដោយវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញទម្រង់ឌី (D) នោះ ត្រូវបញ្ជូនពីនាយកដ្ឋានជំនាញមកចុះហត្ថលេខា ដោយថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម។
- វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញគ្រប់ទម្រង់សម្រាប់នាំចេញទំនិញពីតំបន់សេដ្ឋកិច្ចពិសេស ត្រូវត្រួតពិនិត្យ និងចុះហត្ថលេខាដោយតំណាងក្រសួងពាណិជ្ជកម្ម ប្រចាំនៅរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេសនីមួយៗ ។

**ប្រការ ៣.-**

អគ្គនាយក និងអគ្គនាយករង នៃអគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម ដែលត្រូវបានផ្តល់ភារកិច្ចឲ្យពិនិត្យ និងចុះហត្ថលេខាលើឯកសារដូចមានកំណត់ក្នុងចំណុច២ នៃប្រការ២ ហើយគំរូហត្ថលេខានោះ ត្រូវបានទទួលស្គាល់ដោយប្រទេសនាំចូលរួចហើយ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងពាណិជ្ជកម្ម និងចុះលេខបញ្ជីការតាមនាយកដ្ឋានជំនាញបាន។

ប្រធាន ឬអនុប្រធានមន្ទីរពាណិជ្ជកម្មខេត្ត នៃក្រសួងពាណិជ្ជកម្ម ដែលត្រូវបានផ្តល់ភារកិច្ចឲ្យចុះហត្ថលេខាលើវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញទម្រង់ឌី (D) សម្រាប់នាំចេញទំនិញកសិផល ដោយអ្នកនាំចេញដែលមានទីស្នាក់ការនៅក្នុង ខេត្តស្ថិតក្រោមសមត្ថកិច្ចឆ្លោះទៅកាន់ប្រទេស ដែលមានព្រំដែនជាប់ជាមួយព្រះរាជាណាចក្រកម្ពុជា មានសិទ្ធិ

ប្រើត្រារបស់មន្ទីរពាណិជ្ជកម្មខេត្តបោះនៅលើវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញទម្រង់ឌី (D) ជំនួសឲ្យត្រារបស់ក្រសួងពាណិជ្ជកម្ម។

**ប្រការ ៤.-**

ក្នុងគោលបំណងសម្រួលពាណិជ្ជកម្ម ឯកសារដែលបានពិនិត្យ និងផ្ដល់ការឯកភាពដោយថ្នាក់អនុប្រធាននាយកដ្ឋាន និងអគ្គនាយករង ដែលត្រូវបានចាត់ឲ្យទទួលបន្ទុករួចហើយ ពុំចាំបាច់ដាក់ឆ្លងប្រធាននាយកដ្ឋាន ឬអគ្គនាយកពិនិត្យ និងសម្រេច ជាបន្ថែមទៀតឡើយ។

**ប្រការ ៥.-**

ប្រធាន ឬ អនុប្រធានមន្ទីរពាណិជ្ជកម្មខេត្ត ដែលទទួលបានសិទ្ធិក្នុងចុះហត្ថលេខាលើវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ ទម្រង់ឌី (D) ត្រូវមកបើកយកទម្រង់វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទម្រង់ឌី (D) (Blank C/O Form D) ពីក្រសួងពាណិជ្ជកម្ម ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែសប្ដាហ៍ ត្រីមាស ឆមាស និងឆ្នាំ ស្ដីអំពីចំនួនវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញទម្រង់ឌី (D) ដែលបានចេញជូនក្រុមហ៊ុន និងទិន្នន័យនាំចេញទំនិញកសិផលទាំងអស់ ផ្ញើមកនាយកដ្ឋាននាំចេញ-នាំចូល នៃក្រសួងពាណិជ្ជកម្ម ឲ្យបានទៀងទាត់ ដើម្បីបូកសរុបទិន្នន័យជូនថ្នាក់ដឹកនាំក្រសួង។

**ប្រការ ៦.-**

ប្រកាសទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៧.-**

នាយកខុទ្ទកាល័យ អគ្គាធិការ អគ្គនាយក ប្រធាននាយកដ្ឋាន និង ឯកឧត្តម លោកជំទាវ លោក លោកស្រី ដូចមានចែងក្នុងប្រការ ២ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧ តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែតុលា ឆ្នាំ២០១៦

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

ចម្លងជូនៈ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យ**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី**
- ខុទ្ទកាល័យសម្ដេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី **ស ខេង**
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អាជ្ញាធរសវនកម្មជាតិ
- ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- អង្គភាពប្រឆាំងអំពើពុករលួយ
- អគ្គនាយកដ្ឋានកាំកុងត្រូល
- អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- សភាពាណិជ្ជកម្មកម្ពុជា
- សមាគមរោងចក្រកាត់ដេរនៅកម្ពុជា **"ដើម្បីជូនជ្រាប"**
- ដូចប្រការ ៧ **"ដើម្បីអនុវត្ត"**
- ឯកសារ-កាលប្បវត្តិ